១ពង្សាវតារក្សត្រ១៦:២១-១៧:២៤

# លោកធិបនី និងអ៊ំរីដណ្តើមគ្នាធ្វើស្តេច គ្រងរាជ្យលើសាសន៍អ៊ីស្រាអែល

បន្ទាប់ពីអ៊ំរីក្បត់ចៅហ្វាយរបស់ខ្លួនដោយដណ្តើមរាជបល្ល័ង្ក មានហេតុការណ៍មួយទៀតកើតឡើង គឺលោកធិបនីក៏ចង់ធ្វើជាស្តេចរបស់សាសន៍អ៊ីស្រាអែលដែរ។

**[២១]គ្រានោះ ប្រជាជនទាំងឡាយ ជាសាសន៍អ៊ីស្រាអែល គេបែកគ្នាជា២ពួក ពួក១កាន់ខាងធិបនី ជាកូនគីណាត ប្រាថ្នានឹងលើកឡើងជាស្តេច ហើយពួក១ទៀតកាន់ខាងអ៊ំរី [២២]តែបណ្តាជនដែលចូលដៃខាងអ៊ំរី គេឈ្នះពួកខាងធិបនីជាកូនគីណាត ដូច្នេះធិបនីក៏ស្លាប់ទៅ ហើយអ៊ំរីសោយរាជ្យឡើង (១ពង្សាវតារក្សត្រ ១៦: ២១-២២)។**

លោកអ៊ំរីបានប្រហារជីវិតលោកធិបនីចោល រួចហើយឡើងគ្រងរាជ្យ។ ស្តេចអ៊ំរីឡើងគ្រងរាជ្យបានដប់ពីរឆ្នាំ។ ព្រះគម្ពីរចែងថា ស្តេចអង្គនេះបានប្រព្រឹត្តអំពើ

អាក្រក់លាមកលើសអស់ទាំងស្តេចនានា ដែលធ្លាប់គ្រងរាជ្យលើសាសន៍អ៊ីស្រាអែលកន្លងមក។

**ឯអ័រីទ្រង់ប្រព្រឹត្តដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា ក៏ធ្វើអាក្រក់លើសជាងអស់អ្នកណា ដែលនៅមុនទ្រង់ទៅទៀត (១ពង្សាវតារក្សត្រ១៦:២៥)។**

## ស្តេចអ័ហាប់ឡើងគ្រងរាជ្យ

**[២៨] អ័រីក៏ផុំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ ហើយគេបញ្ចុះទ្រង់នៅក្នុងក្រុងសាម៉ារី រួចអ័ហាប់ ជាព្រះរាជបុត្រាបានសោយរាជ្យឡើងជំនួសបិតា [៣០] អ័ហាប់ ជាបុត្រអ័រី ទ្រង់ប្រព្រឹត្តលាមកអាក្រក់នៅព្រះនេត្រព្រះយេហូវ៉ា លើសជាងអស់អ្នកណាដែលនៅមុនទ្រង់ទៅទៀត (១ពង្សាវតារក្សត្រ១៦: ២៨,៣០)។**

ព្រះបាទអ័រីមានបុត្រាមួយអង្គនាមអ័ហាប់។ ព្រះបាទអ័រីបានប្រព្រឹត្តអំពើលាមកអាក្រក់ លើសជាងអស់ទាំងស្តេចនានាដែលធ្លាប់បានសោយរាជ្យនៅលើសាសន៍

អ៊ីស្រាអែល។ ប៉ុន្តែ ព្រះគម្ពីរបានចែងទៀតថា ស្តេចអ័ហាប់ដែលជាបុត្រារបស់ទ្រង់ បានប្រព្រឹត្តអាក្រក់លាមកជាងបិតាទ្រង់ទៅទៀត។

**ទ្រង់ក៏យកនាងយេសិបិល ជាបុត្រីអេតបាល ស្តេចពួកស៊ីដូន ធ្វើជាភរិយា ព្រមទាំងទៅគោរពប្រតិបត្តិថ្វាយបង្គំដល់ព្រះបាល ផង ទុកដូចជាការ ដែលទ្រង់ប្រព្រឹត្ត តាមអំពើបាបរបស់យេរ៉ូបោម ជាបុត្រនេបាតនោះ ជាការយ៉ាងស្រាលវិញ (១ពង្សាវតារក្សត្រ១៦:៣១)។**

ស្តេចអ័ហាប់ បានប្រព្រឹត្តអំពើអាក្រក់យ៉ាងខ្លាំងជាទីបំផុតនៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់។ ស្តេចអង្គនេះមានមហេសីមួយរូបជួយជ្រោមជ្រែងគ្រប់បែបយ៉ាងដើម្បីអាចធ្វើអំពើអាក្រក់រឹតតែល្អឡើង។ ស្តេចអ័ហាប់ និងនាងយេសិបិល បិនរកគូណាស់។ ពាក្យទំនៀមខ្មែរយើងតែងនិយាយថា "នាងខាតលក្ខណ៍ រត់រកអ្នកកំបាក់អន្សា"។ ការអាក្រក់ណាមួយដែលស្តេចអ័ហាប់គិតមិនដល់ អគ្គមហេសីរបស់ទ្រង់នាមយេសិបិលគិតឃើញទាំងអស់។ នាងយេសិបិល គឺជាស្ត្រីដែលអាក្រក់ជួរជាតិក្នុងចំណោមមនុស្សស្រីដែលធ្លាប់រស់នៅលើលោកនេះ។ ស្តេចអ័ហាប់ដែលចូលចិត្តធ្វើអំពើអាក្រក់ស្រាប់ បាននាងយេសិបិលជាស្រីកាឡកិណី ធ្វើអោយរាជវាំងនៅនគរអ៊ីស្រាអែល ក្លាយត្រឡប់ទៅជាសំបុកចោរនិងពួកអ្នកលេង។ នៅក្នុងប្រវត្តិសាស្ត្រ

យើងឃើញលោក និងលោកស្រីហើម៉ាន ស្តេចហេរ៉ូឌ និងអគ្គមហេសីនាមហេរ៉ូឌាស។ ក្សត្រផត្ទូឡេមី ដាយអូនីសៀស និងនាងក្លេអូប៉ាត ក្សត្រភីលីពទី១ និងនាងម៉ារាកាឡូកិណី សុទ្ធតែជាគូស្រករដែលប្រព្រឹត្តអំពើអាក្រក់លាមកជួរជាតិនៅក្នុងពិភពលោកយើងនេះ។ ប៉ុន្តែ បើប្រៀបធៀបជាមួយនឹងស្តេចអ័ហាប់ ហើយនិងនាងយេសិបិល អ្នកទាំងបួននាក់នោះ មិនស្មើនឹងកូនង៉ែតនៃអំពើអាក្រក់របស់អ្នកទាំងពីរទេ។ នៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សលោកយើងនេះ មានមហាក្សត្រយានីបួនអង្គទៀត ដែលជាមនុស្សអាក្រក់ជួរជាតិខ្លាំងណាស់ដែរ។ មហាក្សត្រយានីខាតទ្រីន ដិមិតដេស៊ី និងមហាក្សត្រហង្សរីទី២ នៃប្រទេសបារាំង មហាក្សត្រីលូគ្រីសសៀរប៊ូជីយ៉ា ត្រូវជាបុត្រីរបស់ស្តេចសង្ឃមួយរូប និងព្រះមហាក្សត្រអាល់ហ្វូនសូ ព្រះមហាក្សត្រម៉ាកបេ៊ស និងព្រះនាងម៉ាបេ៊ស ព្រះមហាក្សត្រល្វីសទី១៦ និងព្រះនាងម៉ារីអាតាណែតនៃប្រទេសបារាំង និងមានប្តីប្រពន្ធមួយទៀត គឺព្រះមហាក្សត្រជូលា និងព្រះនាងអេតថេលរ៉ូស៊ិមប៊ិរ សុទ្ធតែជាមនុស្សដែលប្រព្រឹត្តខូចអាក្រក់លាមកជាទីបំផុតនៅលើលោកនេះ។ ប៉ុន្តែ បើប្រៀបធៀបជាមួយស្តេចអ័ហាប់និងយេសិបិល ស្តេចហើយនិងមហាក្សត្រីទាំងអម្បាលមាណដែលរៀបរាប់មក គ្រាន់តែជាអ្នកខូចបន្ទាប់បន្សំប៉ុណ្ណោះ។ ស្តេចអ័ហាប់និងយេសិបិល វ៉ាដាច់គេដាច់ឯងនៅក្នុងបញ្ជីស្តេចដែលប្រព្រឹត្តអាក្រក់លាមក។

នាងយេសិបិល គឺជាបុត្រីរបស់ស្តេចមួយអង្គនៃនគរស៊ីដូន។ ស្តេចមួយអង្គនោះ ត្រូវជាសម្តេចសង្ឃនៃរូបព្រះបាល។ សម្តេចសង្ឃអង្គនេះ បានសម្លាប់បងប្រុសរបស់ខ្លួន ដើម្បីដណ្តើមយកអំណាចសម្តេចសង្ឃមកកាន់។ តើពាក្យថា យេសិបិលមាន

ន័យថាម៉េច? យេសិបិលមានន័យថា មនុស្សស្រីចិត្តដូចប្រុស ឬជាស្រីកាឡកិណីក៏បាន។ ស្ដេចអ័ហាប់ ហើយនិងនាងយេសិបិលរៀបការដោយមិនមានការស្រឡាញ់គ្នាទេ។ គេរៀបចំ ដើម្បីរក្សាតំណែងនយោបាយរបស់ខ្លួនអោយបានគង់នៅជាស្ដេចផែនដីប៉ុណ្ណោះ។ អ្នកទាំងពីរមិនបានរៀបការជាមួយគ្នាទេ គឺគ្រាន់តែធ្វើពិធីអោយតែគេឃើញប៉ុណ្ណោះ។ នៅលើលោកនេះ កាលណាកូនប្រុសនិងកូនស្រីមិនស្រឡាញ់គ្នាតែត្រូវរៀបការដោយចាប់បង្ខំ អ្នកទាំងពីរមិនបានរៀបការជាមួយគ្នាទេ គឺគ្រាន់តែធ្វើពិធីអោយញាតិមិត្តជិតឆ្ងាយមើលតែប៉ុណ្ណោះ។ ចិត្តអ្នកទាំងពីរមិនបានរៀបការជាមួយគ្នាទេ។ រឿងនេះដូចជាស្ដេចអ័ហាប់ និងនាងយេសិបិលដែរ។ នាងយេសិបិលជាស្រីតែរូបរាងជាប្រុសសុទ្ធសាធ។ នាងមានកិរិយារឹងចចេសមិនចង់ចុះចូលជាមួយនឹងអ្នកណាទេ។ នាងរៀបការជាមួយស្ដេចអ័ហាប់ ពីព្រោះនាងចង់បានតំណែង ដើម្បីគ្រប់គ្រងសាសនារបស់នាងតែប៉ុណ្ណោះ។ នៅក្នុងសង្គមខ្មែរយើង គេហៅស្ត្រីបែបនេះថា"ប្រពន្ធពាក់ផ្កាយ ប្ដីស៊ីបាយបណ្ដើរចោរ"។ នាងយេសិបិលមានចិត្តអាក្រក់លើសជាងអស់ស្ត្រីនានាដែលធ្លាប់កើតនៅលើលោកនេះ។ តើយើងមានភ័ស្តុតាងណាផ្សេងទៀតដែលថា ស្ត្រីរូបនេះពិតជាអាក្រក់មែនដែរឬទេ?

នៅក្នុងព្រះគម្ពីរវិវរណៈ ព្រះអម្ចាស់យេស៊ូវ មានបន្ទូលទៅកាន់ក្រុមជំនុំនៅក្នុងទីក្រុងទាធេរ៉ាថា "តែអញប្រកាន់សេចក្ដីខ្លះនឹងឯង ដ្បិតឯងបណ្ដោយឱ្យស្ត្រីឈ្មោះយេសិបិល ដែលហៅខ្លួនជាហោរា បានទៅបង្ហាត់បង្រៀន ហើយនាំពួកបាវបំរើរបស់អញ ឱ្យវង្វេងទៅប្រព្រឹត្តសេចក្ដីកំផិត ហើយបរិភោគជង្វាយដែលថ្វាយទៅរូបព្រះផង"

(គម្ពីរវិវរណៈ២:២០)។ នាងយេសិបិល គឺជាមនុស្សស្រី តែត្រួតត្រាប្ដី និងមន្ត្រីគ្រប់ជាន់ថ្នាក់ដែលស្ថិតនៅក្រោមអំណាចរបស់ប្ដី។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ព្រមានដល់ទីក្រុងទាធេរ៉ា ពីព្រោះពួកជំនុំនៅទីក្រុងទាធេរ៉ាមិនស្រឡាញ់ដល់ព្រះអម្ចាស់យេស៊ូវយ៉ាងស្និទ្ធស្នាលទេ។ រូបភាពរបស់នាងយេសិបិល គឺសម្ដែងអំពីតំណែងតែប៉ុណ្ណោះ។ នាងមិនដែលមានសេចក្ដីស្និទ្ធស្នាលជាមួយនឹងប្ដីរបស់នាងទេ។

នៅពេលដែលស្ដេចអ័ហាប់សោយរាជ្យ មានរឿងមួយទៀតបានកើតឡើង។ រឿងនោះ បរិយាយនៅក្នុងខគម្ពីរខាងក្រោមនេះ។

> **[៣២] ទ្រង់ក៏ស្អាងអាសនាមួយ ថ្វាយព្រះបាល នៅក្នុងវិហារព្រះបាល**
> **ដែលទ្រង់បានស្អាងនៅក្រុងសាម៉ារី [៣៣] អ័ហាប់ទ្រង់ធ្វើរូបព្រះ**
> **ហើយប្រព្រឹត្តអំពើអាក្រក់ លើសជាងអស់ទាំងស្ដេចដែលនៅមុន**
> **ទ្រង់ទៅទៀត ជាការដែលបណ្ដាលឱ្យព្រះយេហូវ៉ា ជាព្រះនៃពួក**
> **អ៊ីស្រាអែលមានសេចក្ដីក្រោធ [៣៤] នៅក្នុងរាជ្យទ្រង់ នោះហ៊ីអែល**
> **ជាអ្នកក្រុងបេត-អែល ក៏សង់ក្រុងយេរីខូរឡើងវិញ កាលគាត់**
> **ដាក់ជើងកំផែងចុះ នោះអ័ប៊ីរ៉ាម ជាកូនច្បងក៏ស្លាប់ទៅ ហើយ**
> **កាលរៀបចំទ្វារក្រុងឡើង នោះសេគូបជាកូនពៅក៏ស្លាប់ទៅ តាម**
> **សេចក្ដីដែលព្រះយេហូវ៉ាបានមានបន្ទូល ដោយសារយ៉ូស្វេជាកូន**
> **នុន (១ពង្សាវតារក្សត្រ១៦:៣២-៣៤)។**

ស្តេចអ័ហាប់មានបំណងចង់សង់ទីក្រុងយេរីខូរឡើងវិញ។ នៅពេលដែលព្រះជាម្ចាស់បង្គាប់អោយលោកយ៉ូស្វេរំលាយទីក្រុងយេរីខូរចោល ព្រះអង្គអោយលោកយ៉ូស្វេប្រាប់ដល់អ្នកដទៃទៀត ដែលចង់សង់ទីក្រុងឡើងវិញថា "...អ្នកណាដែលចាប់ផ្តើមសង់ទីក្រុងយេរីខូរនេះឡើងវិញ នោះនឹងត្រូវបណ្តាសាហើយ កាលណាអ្នកនោះដាក់ឫសកំផែង នោះកូនច្បងរបស់ខ្លួននឹងស្លាប់ទៅ ហើយកាលណាដាក់ទ្វារចុះនោះកូនពៅនឹងស្លាប់ទៅ" (យ៉ូស្វេ៦:២៦)។ តាំងពីជំនាន់លោកយ៉ូស្វេមកទល់គ្រាដែលស្តេចអ័ហាប់ឡើងគ្រងរាជ្យ មិនដែលនរណាមានចិត្តចង់សង់ទីក្រុងយេរីខូរឡើងវិញទេ ពីព្រោះគេខ្លាចពាក្យបណ្តាសានោះ។ ចំណែកស្តេចអ័ហាប់វិញ មិនជឿដល់ព្រះបន្ទូលទេ។ ស្តេចអង្គនេះនិងភរិយារបស់លោកនាមយេសិបិលនាំគ្នាសាងសង់ទីក្រុងយេរីខូរឡើងវិញ។ ដូច្នេះ សេចក្តីបណ្តាសាដែលព្រះជាម្ចាស់បានសម្រេចឡើងមកដល់អ្នកដែលសង់ទីក្រុងនោះ។ ជាងដែលសង់ទីក្រុងយេរីខូរ ឈ្មោះហ៊ីអែលបានត្រូវបណ្តាសាដោយកូនច្បងរបស់លោកស្លាប់ពេលដាក់កំផែងចុះ រួចហើយពេលរៀបចំដាក់ទ្វារទីក្រុងចុះ កូនពៅរបស់លោកនាមសេគូបក៏ស្លាប់ទៅដែរ។

# ជំពូក ១៧

***ឆាចចនា*** *ហោរាអេលីយ៉ាទាយពីការរាំងស្ងួតបីឆ្នាំ*

*ព្រះជាម្ចាស់ចិញ្ចឹមហោរាអេលីយ៉ា*

*ហោរាអេលីយ៉ាប្រោសកូនស្ត្រីមេម៉ាយម្នាក់អោយមានជីវិតឡើងវិញ*

នៅពេលដែលស្តេចអ័ហាប់និងយេសិបិលគ្រងរាជ្យ ស្តេចនិងមហេសីបានប្រព្រឹត្តអំពើអាក្រក់លាមកជាងស្តេចនានាទាំងអស់ ដែលធ្លាប់សោយរាជ្យមុនទ្រង់។ ប្រឈមមុខជាមួយនឹងស្ថានការណ៍បែបនេះ ព្រះជាម្ចាស់ត្រូវតែរកអ្នកសំណព្វរបស់ទ្រង់មួយរូប ដើម្បីអោយមកឈរនៅក្នុងនគរអ៊ីស្រាអែល។ មនុស្សសំណព្វរបស់ព្រះ ដែលហ៊ានប្រឈមមុខជាមួយនឹងអំពើអាក្រក់របស់ស្តេច ពិតជាមនុស្សមានសេចក្តីក្លាហានបានជាហ៊ានបញ្ចេញមតិ ជំទាស់ជាមួយនឹងអំពើអាក្រក់របស់ស្តេចគ្រងរាជ្យក្នុងនគរអ៊ីស្រាអែល។ ព្រះអង្គត្រៀមអ្នកសំណព្វរបស់ព្រះអង្គម្នាក់ឈ្មោះអេលីយ៉ា។ នៅក្នុងព្រះគម្ពីរ ហោរាអេលីយ៉ាជាអ្នកសំណព្វរបស់ព្រះមួយរូប ដែលមានឥទ្ធិពលយ៉ាងខ្លាំងជាទីបំផុត។ បើតាមបទទំនាយហោរាអេលីយ៉ាអាចជាមនុស្សម្នាក់គត់ ដែលត្រូវយាងត្រឡប់មកវិញធ្វើជាទីបន្ទាល់ក្នុងថ្ងៃចុងក្រោយបង្អស់។

# ហោរាអេលីយ៉ាទាយពីការរាំងស្ងួតបីឆ្នាំ

ព្រះគម្ពីរសម្តែងអោយយើងស្គាល់ហោរាអេលីយ៉ាភ្លាមៗតែម្តង។ ហោរារូបនេះ បង្ហាញខ្លួនដល់ស្តេចអ័ហាប់និងនាងយេសិបិលនៅមុខបល្ល័ង្ករបស់ទ្រង់។ នៅពេលហោរារូបនេះចូលទៅគាល់ស្តេចអ័ហាប់ លោកបានប្រកាសនូវសេចក្តីមួយយ៉ាងក្លាហានជាទីបំផុត។

> **គ្រានោះ អេលីយ៉ា ជាអ្នកស្រុកធេសប៊ី ដែលនៅជាមួយនឹងពួកស្រុកកាឡាត លោកទូលនឹងអ័ហាប់ថា ទូលបង្គំស្បថ ដោយនូវព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលដ៏មានព្រះជន្មរស់ ដែលទូលបង្គំឈរនៅចំពោះទ្រង់នេះថា ក្នុងប៉ុន្មានឆ្នាំទៅមុខនេះ នឹងគ្មានភ្លៀង គ្មានសន្សើមឡើយ វៀរតែដោយសារពាក្យទូលបង្គំប៉ុណ្ណោះ (១ពង្សាវតារក្សត្រ១៧:១)។**

ហោរាអេលីយ៉ាទូលថ្វាយដល់ស្តេចអ័ហាប់ និងនាងយេសិបិលជាមហេសីថា ក្នុងរយៈពេលបីឆ្នាំខាងមុខ នឹងមិនមានភ្លៀង ឬសន្សើមមួយតំណក់ឡើយ។ លុះលោកទូលថ្វាយរឿងនោះដល់ស្តេចអ័ហាប់ និងនាងយេសិបិលរួចហើយ លោកក៏ចាកចេញពីរាជធានីទៅ។ ខ្ញុំជឿថា ស្តេចអ័ហាប់និងនាងយេសិបិល ពិតជាមានការភ្ញាក់ផ្អើល

យ៉ាងខ្លាំង ពីព្រោះអ្នកទាំងពីរមិនដែលគិតនៅក្នុងចិត្តថា មានមនុស្សណាហ៊ានចូលមកនិយាយដាក់ទ្រង់បែបនោះឡើយ។ ស្តេចអ័ហាប់បានអោយគេតាមស៊ើបអង្កេតអោយដឹងថា តើហោរាអេលីយ៉ាធ្លាប់តែនិយាយពាក្យធ្ងន់ៗយ៉ាងដូច្នេះឬ? ហោរាអេលីយ៉ាមិនមានបំណងនិយាយយ៉ាងដូច្នេះ ព្រមទាំងមិនមែនជាមនុស្សដែលតែងតែនិយាយឆៅៗយ៉ាងដូច្នេះឡើយ។

ព្រះជាម្ចាស់ចាំបាច់ត្រូវបង្ហាត់បង្រៀនហោរាអេលីយ៉ា។ ធម្មតាពេលណាព្រះអង្គបង្រៀនបាវបម្រើរបស់ទ្រង់ ទ្រង់តែងតែយកបាវបម្រើរបស់ទ្រង់អោយទៅទទួលការហ្វឹកហ្វឺននៅមហាវិទ្យាល័យទីរហោស្ថាន។ ព្រះអង្គបង្រៀនលោកម៉ូសេសែសិបឆ្នាំនៅទីរហោស្ថានស្រុកម៉ាឌាន។ ព្រះអម្ចាស់ត្រាស់ហៅលោកអ័ប្រាហាំ អោយទៅរៀននៅទីរហោស្ថាននៅស្រុកខាល់ដេ។ ព្រះអង្គបញ្ជូនលោកយ៉ូហាន-បាទីស្ថអោយទៅរៀននៅឯទីរហោស្ថាន។ ព្រះអង្គបញ្ជូនសាវ័កប៉ុល អោយទៅរៀននៅក្នុងទីរហោស្ថានស្រុកអារ៉ាប់អស់រយៈពេលពីរឆ្នាំ មុននឹងប្រើប្រាស់លោក។ វិធីដែលព្រះអម្ចាស់បង្រៀនដល់បាវបម្រើរបស់ទ្រង់ គឺទ្រង់យកលោកទាំងនោះចេញពីទីអ្វូអរទៅបន្ទុំនៅក្នុងទីរហោស្ថាន។ នៅទីនោះព្រះអង្គបង្ហាត់បង្រៀនបាវបម្រើរបស់ព្រះអង្គ ព្រមទាំងបង្កើនគ្រប់ទាំងទេពកោសល្យ ដើម្បីអោយបាវបម្រើព្រះអង្គមានសមត្ថភាពអាចបម្រើព្រះអង្គបាន។ ហោរាអេលីយ៉ា ក៏ដូច្នោះដែរ។ លោកជាមនុស្សក្លាហាន តែព្រះជាម្ចាស់មិនអាចប្រើលោកដោយមានប្រសិទ្ធិភាពបាន ពីព្រោះលោកមានសេចក្ដីក្លាហានពេក។ ព្រះអម្ចាស់ចាំបាច់ត្រូវបញ្ជូនហោរាអេលីយ៉ា ទៅទទួលការបង្វឹកបង្វឹននៅទីរហោស្ថាន

ជាមុនសិន។ តើព្រះជាម្ចាស់បង្រៀនហោរាអេលីយ៉ាអំពីអ្វីខ្លះនៅទីរហោស្ថាន?

## ព្រះជាម្ចាស់ចិញ្ចឹមហោរាអេលីយ៉ា

**២ រួចព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកបង្គាប់លោកថា ៣ ចូរចេញពីទីនេះ បែរទៅខាងកើត ហើយពួនខ្លួននៅឯជ្រោះកេរីត ដែលនៅប្រទល់មុខនឹងទន្លេយ័រដាន់ទៅ (១ពង្សាវតារក្សត្រ១៧:២-៣)។**

ព្រះជាម្ចាស់បង្គាប់អោយអេលីយ៉ាថា ត្រូវរត់គេចខ្លួនអោយបានឆ្ងាយជាទីបំផុត។ ហោរាអេលីយ៉ាស្តាប់បង្គាប់ដល់ព្រះបន្ទូលរបស់ព្រះអង្គ ហើយក៏រត់គេចខ្លួនចូលទៅនៅក្នុងព្រៃស្ងួតសាន កាច់សំបុកនៅក្បែរមាត់អូរតូចមួយ។

**ឯងនឹងផឹកទឹកពីជ្រោះនោះ ហើយអញបានបង្គាប់ឱ្យក្អែកចិញ្ចឹមឯងនៅទីនោះដែរ (១ពង្សាវតារក្សត្រ១៧:៤)។**

ព្រះជាម្ចាស់ប្រើមធ្យោបាយពីរយ៉ាង ដើម្បីចិញ្ចឹមបីបាច់ថែរក្សាដល់ហោរាអេលីយ៉ា ពេលដែលលោកគេចខ្លួនទៅនៅក្នុងព្រៃស្ងួតសាន។ មធ្យោបាយទីមួយ គឺព្រះ

អង្គអោយលោកអេលីយ៉ាប្រើប្រាស់ទឹកដែលមានសល់នៅក្នុងអូរ។ ទឹកអូរគឺជាទឹកដែលព្រះជាម្ចាស់ផ្គត់ផ្គង់តាមលក្ខណៈធម្មជាតិ។ ហោរាអេលីយ៉ាចាំបាច់ត្រូវទទួលទានទឹកអូរដែលព្រះអម្ចាស់ប្រទានមកដោយសារទឹកភ្លៀង ដើម្បីចិញ្ចឹមជីវិត។ មធ្យោបាយមួយទៀត ដែលព្រះជាម្ចាស់ចិញ្ចឹមបីបាច់ថែរក្សាដល់លោកអេលីយ៉ា គឺជាមធ្យោបាយអធិធម្មជាតិ។ ព្រះអង្គប្រើសត្វក្អែក ដើម្បីអោយយកចំណីទៅចិញ្ចឹមលោកអេលីយ៉ា។ លុះលោកស្នាក់នៅក្នុងព្រៃស្ងួតសានអស់មួយរយៈពេល ទឹកអូរនោះក៏រីងស្ងួតទៅ។

> **លុះកន្លងយូរបន្តិចមក ទឹកជ្រោះក៏រីងទៅ ពីព្រោះមិនមានភ្លៀងធ្លាក់នៅស្រុកនោះសោះ (១ពង្សាវតារក្សត្រ១៧:៧)។**

ហោរាអេលីយ៉ាស្នាក់នៅក្នុងព្រៃស្ងួតសាន។ រៀងរាល់ព្រឹកលោកតែងតែអង្គុយមើលទឹកអូរ ដែលចេះតែរីងស្ងួតបន្តិចម្តងៗ។ លោកយកឈើមួយដើមទៅដោតទុក រួចហើយចំណាំមើលថា តើថ្ងៃទីមួយទឹកស្រកអស់ប៉ុន្មាន។ នៅថ្ងៃទីពីរ លោកឃើញថាទឹកស្រកអស់ប៉ុន្មានកម្រិតទៀត។ លុះដល់ថ្ងៃទីបីនិងថ្ងៃជាបន្តបន្ទាប់ លោកគិតឃើញថា ទឹកនេះអាចចិញ្ចឹមលោកតែប៉ុន្មានថ្ងៃទៀតទេ។ មិនយូរប៉ុន្មានលោកនឹងត្រូវស្លាប់ដោយសារគ្មានទឹកទទួលទាន។

ក្រុមជំនុំរបស់ព្រះជាម្ចាស់សព្វថ្ងៃ ពូកែរាយការណ៍ចំនួនមនុស្សខ្លាំងណាស់។ អ្នកដឹកនាំតែងតែនិយាយថា ថ្ងៃនេះមានមនុស្សចំនួនប៉ុន្មាននាក់បានថ្វាយខ្លួន ចំនួន

ប៉ុន្មាននាក់បានរៀនធ្វើជាសិស្ស ចំនួនប៉ុន្មាននាក់ដែលចេញទៅបម្រើព្រះអង្គ។ ប៉ុន្តែ បើយើងសង្កេតមើលតាមស្ថិតិដែលគេរាប់ជាចំនួនមនុស្ស យើងគិតថា ក្រុមជំនុំរបស់ព្រះពិតជារីកដុះដាលយ៉ាងខ្លាំងហើយមើលទៅ។ ផ្ទុយទៅវិញ ស្ថិតិមានតែក្នុងក្រដាស់ទេ ចំណែកឯអ្នកជឿពិតប្រាកដវិញ គ្រាន់តែជាការភូតភររបស់អ្នកធ្វើសេចក្តីរាយការណ៍តែប៉ុណ្ណោះ។ សព្វថ្ងៃនេះ បញ្ហាស្ថិតិ ជាអំពើបាបមួយយ៉ាងធ្ងន់ជាទីបំផុត ដែលក្រុមជំនុំរបស់ព្រះតែងតែយកមកធ្វើជាខ្នាតរង្វាស់ ដើម្បីអោយដឹងថា ក្រុមជំនុំរបស់ព្រះអង្គរីកចម្រើន ឬមួយយ៉ាងណា។ ស្ថិតិ មិនមែនជាខ្នាតរង្វាស់សម្រាប់វាស់មើលទំហំរបស់ក្រុមជំនុំនៃព្រះទេ។ ស្ថិតិមានច្រើនមែន តែផ្ទៃក្នុងរបស់ពួកអ្នកជឿប្រហែលជាមិនបានលូតលាស់ដូចស្ថិតិនោះឡើយ។

ហោរាអេលីយ៉ាជឿលើស្ថិតិ។ បើតាមស្ថិតិលោកគិតថា លោករស់មិនបានប៉ុន្មានថ្ងៃទៀតទេ ពីព្រោះទឹកនេះនឹងរីងស្ងួតអស់ទៅ។ ស្ថិតិមិនអាចយកមកធ្វើជាគោលខាងព្រលឹងវិញ្ញាណរបស់អ្នកជឿជាដាច់ខាត។ លោកអ្នកមិនអាចវាស់ការចម្រើនលូតលាស់របស់ក្រុមជំនុំ ជាមួយនឹងក្បួនទិន្នន័យណាមួយឡើយ។ លោកអ្នកក៏មិនអាចវាស់ការចម្រើនលូតលាស់របស់ក្រុមជំនុំក្នុងម៉ាស៊ីនកុំព្យូទ័របានដែរ។ រីឯការភ្ញាក់រលឹកដែលព្រះជាម្ចាស់ដាស់តឿនដល់មនុស្សលោកវិញ ក៏មិនអាចវាស់ជាចំនួនមនុស្សកើត។ នៅពេលហោរាអេលីយ៉ាសង្កេតឃើញទឹកអូរចេះតែរីងស្ងួតទៅៗ ព្រះជាម្ចាស់ក៏បង្រៀនដល់លោក។ លោកយល់ថា ជីវិតរបស់មនុស្សគ្រប់រូប ប្រៀបឧបមាដូចជាអូរ ដែលកំពុងរីងទឹកបន្តិចម្តងៗ។ អូរមិនរាប់ថាជាអូរទៀតទេ បើគ្មានទឹកហូរនៅក្នុងពោះអូរ។

មនុស្សលោកប្រៀបឧបមាដូចជាអូរមួយ។ អូរនោះគ្មានប្រយោជន៍អ្វីទេ បើសិនជាគ្មានទឹកជីវិតហូរក្នុងពោះខ្លួន។ ឯទឹកជីវិតនោះទៀតសោត គឺជីវិតអស់កល្បជានិច្ចនៅក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះអម្ចាស់យេស៊ូវបង្រៀនយើងអំពីទឹកជីវិតនេះថា "...អស់អ្នកណាដែលផឹកទឹកនេះ នឹងត្រូវស្រេកទៀត តែអ្នកណាដែលផឹកទឹកខ្ញុំឱ្យ នោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឱ្យ នឹងត្រឡប់ជារន្ធទឹកនៅក្នុងអ្នកនោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច" (យ៉ូហាន៤:១៣-១៤)។ យើងជាមនុស្សលោករស់នៅមែន ក៏ប៉ុន្តែ រស់តែមួយជីវិតនេះប៉ុណ្ណោះ។ លុះទឹកជីវិតនៅក្នុងលោកនេះរីងស្ងួតអស់ពីយើងទៅ យើងនឹងស្លាប់បាត់បង់ជីវិតទៅដែរ។ ប៉ុន្តែ អ្នកណាដែលមានទឹកជីវិត គឺជាព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទគង់នៅក្នុងចិត្តខ្លួន អ្នកនោះមិនស្លាប់ទេ ទោះបីរូបកាយនេះត្រូវស្លាប់ថ្ងៃណាមួយក៏ពិតមែន។ រូបកាយរបស់លោកអ្នកគ្រាន់តែជាអូរមួយប៉ុណ្ណោះ។ លោកអ្នកចាំបាច់ត្រូវមានទឹកជីវិតនៃព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទហូរនៅក្នុងអូរលោកអ្នក ទើបលោកអ្នកអាចរស់នៅជាមួយនឹងព្រះអង្គអស់កល្បជានិច្ចតរៀងទៅ។ បើយើងមិនទទួលស្គាល់ថា ខ្លួនយើងជាអូរគ្មានទឹកទេ នោះយើងមិនទទួលស្គាល់ថា យើងជាមនុស្សមានបាបឡើយ។ ព្រះជាម្ចាស់ចាំបាច់ត្រូវបង្រៀនហោរាអេលីយ៉ាថា"...ទ្រង់បានរើសពួកកំសោយនៅលោកីយនេះ ដើម្បីនឹងធ្វើឱ្យពួកខ្លាំងពូកែមានសេចក្ដីខ្មាស" (១កូរិនថូស១:២៧)។ ព្រះជាម្ចាស់ចង់មានបន្ទូលទៅកាន់ហោរាអេលីយ៉ាថា "ឯងមិនមានអ្វីនៅក្នុងខ្លួនឯងទេ គឺឯងគ្រាន់តែជាអូរដែលគ្មានទឹកមួយប៉ុណ្ណោះ។ ឯងចាំបាច់ត្រូវមានទឹករបស់អញ ហូរកាត់ឯង ទើបឯងមានចេស្ដានឹងរស់នៅ"។

បេសកនៅ”។ ជនដ៏ល្បីល្បាញមួយរូបនាមលោកហាត់សិនថេល័រ អធិប្បាយប្រាប់ដល់បេសកជនវ័យក្មេងថា “មុននឹងអ្នករាល់គ្នាធ្វើដំណើរចេញទៅបម្រើព្រះអង្គ អ្នករាល់គ្នាត្រូវយល់ថា អ្នករាល់គ្នាមិនមានអ្វីនៅក្នុងខ្លួនទេ។ បើព្រះជាម្ចាស់មិនបំពេញចេស្តាអោយអ្នករាល់គ្នាទេ អ្នករាល់គ្នាគ្មានប្រយោជន៍អ្វីនឹងចេញទៅបម្រើព្រះអង្គឡើយ”។ ពិតប្រាកដណាស់! អ្នកបម្រើព្រះអង្គគ្រប់រូប ត្រូវទទួលស្គាល់ថា ក្នុងខ្លួនយើងគ្មានចេស្តាអ្វីទេ ពោលគឺគ្រាន់តែជាអូរមួយ ដែលគ្មានទឹកប៉ុណ្ណោះ។ យើងចាំបាច់ត្រូវការទឹកនៃព្រះបន្ទូលរបស់ព្រះអង្គហូរកាត់យើង ទើបយើងមានកម្លាំងបម្រើព្រះអង្គ។

ក្រោយពីទ្រង់បង្រៀនមេរៀនទីមួយហើយ ព្រះអង្គក៏បញ្ជូនលោកអេលីយ៉ាអោយទៅកន្លែងមួយទៀត។

**៨នោះព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកបង្គាប់លោកថា ៩ចូរក្រោក**
**ឡើង ទៅឯសារិបតា ជាទីក្រុងរបស់ពួកស៊ីដូនអាស្រ័យនៅទី**
**នោះវិញចុះ អញបានបង្គាប់ស្រីមេម៉ាយម្នាក់នៅទីនោះ ឱ្យចិញ្ចឹម**
**ឯង ១០ដូច្នេះ លោកក៏ក្រោកឡើងទៅឯក្រុងសារិបតា កាលបាន**
**ទៅដល់មាត់ទ្វារក្រុងហើយ នោះឃើញមានស្រីមេម៉ាយម្នាក់**
**កំពុងតែរើសរំកាច់ឈើ លោកក៏ហៅនាងថា សូមយកទឹកក្នុងផ្តិល**
**មកឱ្យខ្ញុំផឹកបន្តិច ១១កាលនាងកំពុងតែទៅយកទឹក នោះលោក**
**ស្រែកផ្តាំថា សូមយកនំបុ័ងបន្តិចមកឱ្យខ្ញុំផង ១២តែនាងឆ្លើយថា**

**ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ជាព្រះនៃអ្នកដ៏មានព្រះជន្មរស់នៅថា ខ្ញុំគ្មាន១ដុំឡើយ មានតែម្សៅ១ក្តាប់នៅក្នុងខាប់ នឹងប្រេងបន្តិចបន្តួចនៅដបប៉ុណ្ណោះ មើលនែ ខ្ញុំកំពុងតែរើសរំកាច់ឈើ២នេះ ដើម្បីចូលទៅចំអិនសំរាប់ខ្ញុំនឹងកូន យើងនឹងបរិភោគតែប៉ុណ្ណោះ រួចស្លាប់ទៅ (១ពង្សាវតារក្សត្រ១៧:៨-១២)។**

លោកអេលីយ៉ាធ្វើដំណើរទៅផ្ទះស្រីមេម៉ាយម្នាក់ រួចហើយបង្គាប់អោយនាងធ្វើនំខ្លះអោយលោកពិសា។ ស្រីមេម៉ាយនោះថ្លែងប្រាប់ហោរាអេលីយ៉ាថា នាងមិនមានម្សៅអីធ្វើនំទេ ពោលគឺបន្តិចទៀតនាងក៏ស្លាប់ដែរ។

**១៣តែអេលីយ៉ាប្រាប់នាងថា កុំឱ្យខ្លាចឡើយ សូមទៅធ្វើដូចជាអ្នក
បានថាចុះ តែសូមធ្វើនំ១យ៉ាងតូចមកឱ្យខ្ញុំជាមុនសិន រួចសឹមធ្វើ
សំរាប់អ្នក នឹងកូនអ្នកចុះ ១៤ដ្បិតព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា ម្សៅក្នុងខាប់នោះនឹងមិន
ដែលផុតទៅ ហើយប្រេងក្នុងដបក៏មិនដែលរលោះឡើយ ដរាប
ដល់ថ្ងៃដែលព្រះយេហូវ៉ានឹងបង្អុរភ្លៀងមកលើផែនដី (១ពង្សាវ
តារក្សត្រ១៧:១៣-១៤)។**

លោកអេលីយ៉ាបង្គាប់អោយស្ត្រីមេម៉ាយនោះ  បោសម្សៅដែលមានសល់នៅបាតខាប់ ធ្វើនំអោយលោកពិសាផង។ ព្រះជាម្ចាស់បានបង្ហាត់បង្រៀនដល់លោកអេលីយ៉ានូវមេរៀនទីពីរដូចខាងក្រោមនេះ។

ហោរាអេលីយ៉ាមិនមែនជានរណាក្រៅអំពីខាប់ដែលគ្មានម្សៅនោះទេ។ ព្រះជាម្ចាស់ចាំបាច់ត្រូវប្រើមនុស្សណាដែលទទួលស្គាល់ថាខ្លួនជាខាប់ដែលគ្មានម្សៅ។ ព្រះជាម្ចាស់អាចបំពេញខាប់នោះ រួចហើយទ្រង់នឹងប្រើអ្នកនោះទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។ បញ្ហាដែលយើងកំពុងមានសព្វថ្ងៃ គឺបាវបម្រើព្រះអង្គភាគច្រើននៅក្នុងក្រុមជំនុំ ពូកែពេក ឆ្លាតពេក វាងវៃពេក បានជាព្រះអម្ចាស់ប្រើមិនកើត។ យើងចាំបាច់ត្រូវរំឭកខ្លួនឯងថា យើងគ្រាន់តែជាខាប់ដែលគ្មានម្សៅតែប៉ុណ្ណោះ ទើបព្រះអង្គប្រើយើងកើត។

## ហោរាអេលីយ៉ាប្រោសកូនស្ត្រីមេម៉ាយម្នាក់<br>អោយមានជីវិតឡើងវិញ

**ក្រោយនោះមក មានកាល១ថ្ងៃ កូនរបស់នាងម្ចាស់ផ្ទះនោះចាប់ជំងឺឈឺ ជំងឺនោះមានទំងន់ណាស់ ដល់ម្ល៉េះបានជាគ្មានដង្ហើមក្នុងខ្លួនទៀតឡើយ (១ពង្សាវតារក្សត្រ១៧:១៧)។**

កូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់នោះ ក៏ស្លាប់ទៅ។ តើលោកអេលីយ៉ាធ្វើដូចម្ដេច?

**[19]តែលោកឆ្លើយតបថា សូមឱ្យកូនអ្នកមកខ្ញុំចុះ រួចលោកក៏ទទួល**
**កូនពីទ្រូងនាង បីឡើងចូលទៅក្នុងបន្ទប់ ដែលលោកអាស្រ័យនៅ**
**ហើយផ្ដេកនៅលើដំណេករបស់លោក [20]រួចអំពាវនាវដល់ព្រះ**
**យេហូវ៉ាថា ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ តើទ្រង់បាន**
**នាំសេចក្ដីអាក្រក់មកលើស្រីមេម៉ាយនេះ ដែលទូលបង្គំអាស្រ័យ**
**នៅជាមួយដោយសំឡាប់កូននាងដែរឬ [21]លោកក៏ទ្រាបលើកូន**
**នោះ៣ដង ទាំងអំពាវនាវដល់ព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ា**
**ជាព្រះនៃទូលបង្គំអើយ សូមឱ្យព្រលឹងរបស់កូននេះត្រឡប់ចូល**
**មកក្នុងខ្លួនវាវិញចុះ [22]ព្រះយេហូវ៉ាទ្រង់ស្ដាប់តាមអេលីយ៉ា**
**ហើយព្រលឹងរបស់កូននោះ ក៏ត្រឡប់ចូលមកក្នុងខ្លួនវា ឱ្យរស់**
**ឡើងវិញ (១ពង្សាវតារក្សត្រ១៧:១៩-២២)។**

លោកអេលីយ៉ា បានយករូបកាយរបស់លោកទៅទ្រាបលើរូបកាយរបស់ក្មេងនោះចំនួនបីដង។ សេចក្ដីនេះ សម្ដែងអំពីព្រះអម្ចាស់យេស៊ូវដែលត្រូវសុគត យកព្រះអង្គទៅបញ្ចុះនៅក្នុងផ្នូរចំនួនបីថ្ងៃ រួចហើយព្រះអង្គរស់ឡើងវិញ។ បើព្រះអម្ចាស់យេស៊ូវគ្រីស្ទ មិនសុគត ហើយរស់ឡើងវិញទេ រូបកាយរបស់យើងគ្រប់គ្នាគ្រាន់តែ

ជាខ្មោចដែលស្លាប់ទៅ ហើយរលាយទៅជាដីតែប៉ុណ្ណោះ។ យើងគ្រប់គ្នាជាមនុស្សមានបាប ត្រូវស្លាប់ក្នុងអំពើបាបរបស់យើង។ ប៉ុន្តែព្រះអម្ចាស់យេស៊ូវបានយករូបកាយរបស់ទ្រង់ទៅប្រគល់អោយគេធ្វើគុតទ្រង់នៅលើឈើឆ្កាង ដើម្បីប្តូររូបកាយរបស់យើង។ ទ្រង់សុគតតែបីថ្ងៃ ហើយទ្រង់រស់ឡើងវិញ។ ដោយសាររូបកាយរបស់ព្រះអង្គត្រូវសុគត រូបកាយរបស់យើងក៏ត្រូវស្លាប់។ ប៉ុន្តែ ដោយសាររូបកាយរបស់ទ្រង់រស់ឡើងវិញ រូបកាយរបស់យើងក៏រស់ឡើងវិញដែរ។ បើព្រះអម្ចាស់យេស៊ូវមិនរស់ពីសុគតវិញ ហើយបើយើងមិនបានប៉ះរូបកាយរបស់ព្រះអម្ចាស់យេស៊ូវដោយជំនឿទេ យើងគ្រាន់តែជាខ្មោចមួយ ដែលរូបកាយរលាយទៅជាដីតែប៉ុណ្ណោះ។ ព្រះជាម្ចាស់មានបន្ទូលតាមរយៈសាវ័កប៉ុល ស្តីអំពីដំណើរនេះថា "ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែ ខ្ញុំរស់នៅមិនមែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ..." (កាឡាទី២:២០)។

ព្រះជាម្ចាស់ចាំបាច់ត្រូវបង្ហាត់បង្រៀនសេចក្តីបីយ៉ាងដល់លោកអេលីយ៉ា មុននឹងទ្រង់បញ្ជូនលោកអោយទៅបម្រើទ្រង់។ ទីមួយ ព្រះអង្គបង្រៀនអោយអេលីយ៉ាដឹងថា លោកគ្រាន់តែជាអ្ងរមួយ ដែលគ្មានទឹកប៉ុណ្ណោះ។ ទីពីរ ព្រះអង្គបង្រៀនលោកអេលីយ៉ាថា លោកគ្រាន់តែជាខាប់ដែលគ្មានម្សៅ។ ឯទីបី ទ្រង់បង្រៀនដល់ហោរាអេលីយ៉ាថា រូបកាយរបស់លោក បើគ្មានព្រះអម្ចាស់យេស៊ូវទេ លោកគ្រាន់តែជាខ្មោចបុគ្គលម្នាក់ប៉ុណ្ណោះ។ លុះអេលីយ៉ារៀននូវមេរៀនទាំងបីនេះរួចហើយ ទើបព្រះអម្ចាស់យេស៊ូវអាចប្រើប្រាស់លោកបាន។ អ្នកប្រាជ្ញគម្ពីរមួយរូបដែលជាបិតានៃចលនាប្រូតេស្តង់នាមលោកម៉ាកទិនលូទ័រ មានប្រសាសន៍ថា ព្រះជាម្ចាស់បង្កើតយើងគ្រប់គ្នាពីរបស់

ដែលគ្មានសោះ។ ទាល់តែយើងទទួលស្គាល់ថា យើងមិនមែនជានរណាម្នាក់ ទើបព្រះអម្ចាស់អាចប្រើប្រាស់យើងបាន។ បញ្ហាដែលយើងមានសព្វថ្ងៃគឺយើងមានកម្លាំងខ្លាំងពេក យើងមានប្រាជ្ញាហួសហេតុ ព្រមទាំងយើងចេះដឹងជ្រុល ទើបព្រះជាម្ចាស់មិនអាចប្រើយើងបាន។

យើងស្លេះការសិក្សាគម្ពីរ១ពង្សាវតារក្សត្រត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"